ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.៣៩១.....សហវ.ប្រកាសអាជ្ញា

ប្រកាស
ស្តីពី
កណ្តាគារគយមានដែនកំណត់

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការដំឡើង សាខាគយនិងរដ្ឋាករចំនួន ២ ទៅជានាយកដ្ឋានស្ថិតក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករ កម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១១៦ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីកណ្តាគារគយ មានដែនកំណត់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញប្រកាសលេខ ១៦៣ សហវ.ប្រក.អគរ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាពថ្នាក់ក្រោមនាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩៥៨ សហវ.ប្រក.អគរ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ ១.-

កំណត់នីតិវិធីនៃការបង្កើត ការផ្តល់អាជ្ញាបណ្ណ និងកិច្ចដំណើរការនៃ **កណ្តាគារគយមានដែនកំណត់** ដោយអនុលោមតាមបញ្ញត្តិមាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និងមាត្រា ៤៩ នៃច្បាប់ស្តីពីគយ។

កណ្តាគារគយមានដែនកំណត់ គឺជាអគារ ទីកន្លែង ឬទីលាន ដែលទទួលបានការអនុញ្ញាតឱ្យធ្វើសន្និធិទំនិញ ក្រោមការត្រួតពិនិត្យរបស់គយសម្រាប់រយៈពេលជាក់លាក់មួយ និងដោយមានបញ្ជាក់ពីពេលវេលាច្បាស់លាស់។ ទំនិញនាំចូល និងទំនិញក្នុងស្រុកសម្រាប់នាំចេញ អាចត្រូវបានដាក់ក្នុងកណ្តាគារគយមានដែនកំណត់។

ប្រការ ២ .-

ទំនិញក្នុងកណ្តាគារគយមានដែនកំណត់ ត្រូវបានព្យួរពន្ធនិងអាករដែលត្រូវជាប់។ ការហាមឃាត់ឬការដាក់កម្រិតកំណត់នានាលើទំនិញទាំងនេះ អាចត្រូវបានលើកលែងរហូតដល់ពេលដែលទំនិញត្រូវបានបញ្ចេញពីគយសម្រាប់ការប្រើប្រាស់ក្នុងប្រទេស ឬដើម្បីនាំចេញ។

ប្រការ ៣ .-

កណ្តាគារគយមានដែនកំណត់មានបីប្រភេទ៖

- ប្រភេទ **ក** : កណ្តាគារសាធារណៈ គឺជាកណ្តាគារគយមានដែនកំណត់ដែលទទួលបានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលអាចធ្វើប្រតិបត្តិការដោយភ្នាក់ងាររបស់រាជរដ្ឋាភិបាល ឬដោយបុគ្គលណាមួយ។ កណ្តាគារនេះត្រូវបានប្រើប្រាស់សម្រាប់ផ្តល់សេវាដល់បុគ្គលណាមួយ ដែលមានសិទ្ធិស្របច្បាប់លើទំនិញ ឱ្យធ្វើសន្និធិទំនិញ រាប់បញ្ចូលទាំងអ្នកនាំចូល បុគ្គលដែលទិញទំនិញក្នុងកណ្តាគារនេះ ឬបុគ្គលណាមួយផ្សេងទៀតដែលមានសិទ្ធិស្របច្បាប់លើទំនិញទាំងនេះ។

- ប្រភេទ **ខ** : កណ្តាគារឯកជន គឺជាកណ្តាគារគយមានដែនកំណត់ដែលទទួលបានការអនុញ្ញាតពីអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវបានប្រើប្រាស់ដោយឡែកដោយបុគ្គលណាម្នាក់សម្រាប់ធ្វើសន្និធិទំនិញ ដើម្បីការប្រើប្រាស់ដោយឡែក រាប់បញ្ចូលទាំងប្រតិបត្តិករអគារលក់ទំនិញរួចពន្ធ។

- ប្រភេទ គ : កណ្តាគារពិសេស គឺជាភណ្ឌាគារគយមានដែនកំណត់ដែលទទួលបានការអនុញ្ញាតពីអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សម្រាប់រក្សាប្រភេទទំនិញគ្រោះថ្នាក់ ប៉ះពាល់ដល់គុណភាពទំនិញដទៃទៀត ឬអាចត្រូវការទីកន្លែងពិសេសសម្រាប់រក្សាទំនិញទាំងនោះ។ ភណ្ឌាគារគយប្រភេទនេះ អាចជាភណ្ឌាគារសាធារណៈ ឬឯកជន។

ប្រការ ៤ .-

អាជ្ញាបណ្ណសម្រាប់ភណ្ឌាគារគយមានដែនកំណត់ត្រូវកំណត់នូវលក្ខខណ្ឌនៃកិច្ចសន្យា និងប្រតិបត្តិការធុរកិច្ច រវាងរដ្ឋបាលគយ និងប្រតិបត្តិករភណ្ឌាគារគយមានដែនកំណត់។ កិច្ចសន្យានេះត្រូវកំណត់នូវ ៖

- សិទ្ធិ ភារកិច្ច និងកាតព្វកិច្ច របស់ភាគីនីមួយៗ
- ទីតាំងនៃភណ្ឌាគារគយមានដែនកំណត់
- រយៈពេលប្រតិបត្តិការ និងលទ្ធភាពនៃការពន្យារសុពលភាព
- គម្រោងអគារ និងផែនទីការដ្ឋាន
- ទម្រង់ និងចំនួនទឹកប្រាក់នៃនិមុត្តិធានា
- នីតិវិធីសម្រាប់ចាត់ចែង និងគ្រប់គ្រង
- បែបបទនៃការដឹកជញ្ជូនឆ្លងកាត់
- មុខទំនិញដែលត្រូវអនុញ្ញាតឱ្យដាក់នៅក្នុងភណ្ឌាគារគយ
- ការតម្រូវឱ្យធ្វើប្រតិវេទន៍គយ
- លក្ខខណ្ឌផ្សេងទៀតដែលអាចតម្រូវដោយរដ្ឋបាលគយ។

ប្រការ ៥ .-

បុគ្គលណាមួយមានបំណងបំពេញធុរកិច្ចជាប្រតិបត្តិករភណ្ឌាគារគយមានដែនកំណត់ត្រូវស្នើសុំទៅអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តាមទម្រង់កំណត់ដោយភ្ជាប់ជាមួយនូវ គម្រោងប្លង់សំណង់លម្អិត និងទីតាំងដែលត្រូវសាងសង់ភណ្ឌាគារនោះ។

អាជ្ញាបណ្ណអាចត្រូវផ្តល់ជូនបាន ក្នុងករណីដែលលក្ខខណ្ឌខាងក្រោមនេះ ត្រូវបានបំពេញ៖

- អ្នកស្នើសុំត្រូវមានលិខិតថ្កោលទោស ដែលចេញដោយស្ថាប័នមានសមត្ថកិច្ច
- អ្នកស្នើសុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីផ្តល់នូវ ទីកន្លែង សម្ភារៈបរិក្ខារ ឧបករណ៍បុគ្គលិក និងសេវាកម្ម ចាំបាច់នានាសម្រាប់កិច្ចដំណើរការភណ្ឌាគារគយមានដែនកំណត់
- អ្នកស្នើសុំមានប្រវត្តិអនុលោមភាពលើកាតព្វកិច្ចសារពើពន្ធស្អាតស្អំ
- រដ្ឋបាលគយពិនិត្យឃើញថា សំណើសុំនេះមានប្រសិទ្ធភាពសេដ្ឋកិច្ច
- ទីតាំងភណ្ឌាគារគយដែលស្នើសុំ ស្ថិតនៅចម្ងាយសមស្របមួយពីផ្លូវគមនាគមន៍សំខាន់ៗ និងពីការិយាល័យគយ មានទីធ្លាសមល្មមសម្រាប់ធ្វើសន្និធិទំនិញប្រកបដោយសុវត្ថិភាព
- រដ្ឋបាលគយអាចគ្រប់គ្រង និងផ្តល់សេវាកម្មបានក្នុងភណ្ឌាគារនេះ។

អាជ្ញាបណ្ណអាចត្រូវបានកែសម្រួល ឬបំពេញបន្ថែមដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងគោលបំណង៖

- ផ្លាស់ប្តូរនូវការដាក់កម្រិតកំណត់ ឬលក្ខខណ្ឌនានាក្នុងអាជ្ញាបណ្ណពាក់ព័ន្ធនឹងទំនិញដែលអាចត្រូវបានអនុញ្ញាតឱ្យដាក់ក្នុងភណ្ឌាគារ ឬដើម្បីបញ្ជាក់នូវកម្រិតកំណត់នូវលក្ខខណ្ឌទាំងនេះ
- ផ្លាស់ប្តូរនាមករណ៍អ្នកទទួលអាជ្ញាបណ្ណក្នុងករណីចាំបាច់។

អាជ្ញាបណ្ណអាចត្រូវបានបដិសេធដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រសិនបើអ្នកទទួលអាជ្ញាបណ្ណ៖

- លែងជាម្ចាស់កម្មសិទ្ធិ ឬជាអ្នកជួល ទិញ ទីកន្លែងដែលត្រូវបានផ្តល់អាជ្ញាបណ្ណជាភណ្ឌាគារគយមានដែនកំណត់
- ស្នើសុំជាលាយលក្ខណ៍អក្សរទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបដិសេធអាជ្ញាបណ្ណ
- ត្រូវបានក្សីយធន។

អាជ្ញាបណ្ណអាចត្រូវបានព្យួរ ឬបដិសេធ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រសិនបើអ្នកទទួលអាជ្ញាបណ្ណ៖

- ជាកម្មវត្ថុនៃការបង្ខំឱ្យសងបំណុលតាមផ្លូវតុលាការ
- មិនបានបំពេញតាមបញ្ញត្តិនៃប្រកាសនេះ
- ប្រព្រឹត្តល្មើសនឹងបញ្ញត្តិនៃច្បាប់ ឬបទប្បញ្ញត្តិនានាជាធរមានពាក់ព័ន្ធទៅនឹងការនាំចូល ឬការនាំចេញទំនិញ
- ប្រព្រឹត្តភាពមិនស្មោះត្រង់ក្នុងធុរកិច្ចរបស់ខ្លួនជាមួយជើងសាគយ អ្នកនាំចូល អ្នកនាំចេញ អ្នកដឹកជញ្ជូន ឬស្ថាប័ននានារបស់រាជរដ្ឋាភិបាល
- គ្មានសមត្ថភាពគ្រប់គ្រងកិច្ចដំណើរការភណ្ឌាគារគយមានដែនកំណត់
- ពុំមានទំនិញគ្រប់គ្រាន់សម្រាប់ជានានិរន្តរភាពនៃកិច្ចប្រតិបត្តិការភណ្ឌាគារគយមានដែនកំណត់
- រដ្ឋបាលគយពុំមានលទ្ធភាពផ្តល់សេវាកម្មដល់ភណ្ឌាគារគយមានដែនកំណត់នោះតទៅទៀត។

នៅពេលដែលអាជ្ញាបណ្ណត្រូវបានព្យួរ ភណ្ឌាគារគយមានដែនកំណត់នឹងមិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការ ហើយរដ្ឋបាលគយ អាចចាក់សោ និងបិទត្រាគយលើភណ្ឌាគារនេះសម្រាប់រយៈពេលនៃការព្យួរអាជ្ញាបណ្ណ។

ប្រការ ៦ .-

ប្រតិបត្តិការភណ្ឌាគារគយមានដែនកំណត់ ត្រូវបង់កម្រៃអាជ្ញាបណ្ណតាមបទប្បញ្ញត្តិជាធរមាន និងត្រូវបង់កម្រៃគ្រប់គ្រងប្រតិបត្តិការភណ្ឌាគារគយមានដែនកំណត់ ស្មើនឹងមួយភាគរយ (១%) នៃប្រាក់ពន្ធនិងអាករជាមធ្យមប្រចាំខែដែលត្រូវជាប់លើទំនិញក្នុងភណ្ឌាគារគយមានដែនកំណត់ ឬយ៉ាងតិចពីរ (២)លានរៀល។ កម្រៃនេះត្រូវបង់នៅរាល់ដំណាច់ឆ្នាំសារពើពន្ធនីមួយៗ។ ប្រសិនបើអាជ្ញាបណ្ណត្រូវបានចេញក្រោយថ្ងៃទីមួយខែកក្កដា កម្រៃអាជ្ញាបណ្ណសម្រាប់ឆ្នាំសារពើពន្ធនោះត្រូវស្មើនឹងពាក់កណ្តាលនៃកម្រៃប្រចាំឆ្នាំ។

ប្រការ ៧ .-

ប្រតិបត្តិករភណ្ឌាគារគយមានដែនកំណត់ ត្រូវតម្កល់និមុត្តិធានាជូនរដ្ឋបាលគយជាសាច់ប្រាក់ចំនួនបីរយ (៣០០)លានរៀល។

ប្រការ ៨ .-

ប្រតិបត្តិករភណ្ឌាគារគយមានដែនកំណត់ ត្រូវទទួលបន្ទុកលើការចំណាយពាក់ព័ន្ធនឹងកិច្ចដំណើរការ ការថែរក្សា និងជួសជុលភណ្ឌាគារ ហើយត្រូវធានាដោះស្រាយទីកន្លែងសមរម្យ គ្រប់គ្រាន់ដោយមិនយកកម្រៃជូនមន្ត្រីគយដើម្បីបំពេញការងាររបស់ខ្លួន។

ប្រតិបត្តិករភណ្ឌាគារគយមានដែនកំណត់ត្រូវផ្តល់បុគ្គលិក និងសម្ភារៈបរិក្ខារចាំបាច់ជូនមន្ត្រីគយសម្រាប់ការត្រួតពិនិត្យទំនិញឱ្យបានត្រឹមត្រូវ និងត្រូវមានបុគ្គលិកគ្រប់គ្រាន់សម្រាប់គ្រប់គ្រងភណ្ឌាគារ ថែរក្សាឯកសារ និងបញ្ជីស្នាមគណនេយ្យ និងផ្តល់ឯកសារទាំងនោះជូនមន្ត្រីគយរាល់ពេលមានតម្រូវការ។

ភណ្ឌាគារគយមានដែនកំណត់ត្រូវមានសុវត្ថិភាពដោយមានការចាក់សោទ្វារ និងបង្ហួច។ ទំនិញត្រូវតែបានសន្និធិប្រកបដោយសុវត្ថិភាព ហើយនីតិវិធីសមស្របមួយត្រូវបានដាក់ឱ្យអនុវត្តដើម្បីរក្សាសន្តិសុខ។ ការចេញចូលភណ្ឌាគារនេះត្រូវបានអនុញ្ញាតសម្រាប់តែបុគ្គលមួយចំនួន តាមការកំណត់របស់រដ្ឋបាលគយប៉ុណ្ណោះ។

ប្រការ ៩ .-

ប្រតិបត្តិករភណ្ឌាគារគយមានដែនកំណត់ ត្រូវថែរក្សាសំណុំឯកសារនានានៃទំនិញទាំងអស់ដែលធ្វើសន្និធិក្នុងភណ្ឌាគារនេះ ដោយអនុលោមតាមការតម្រូវរបស់រដ្ឋបាលគយ និងត្រូវធានាឱ្យមានការគ្រប់គ្រង និងត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពនៅនឹងកន្លែងដើម្បីបង្ការនូវការបាត់បង់ទំនិញ។

សំណុំឯកសាររបស់ប្រតិបត្តិករ ត្រូវបង្ហាញនូវចលនាទំនិញដែលស្ថិតក្រោមការគ្រប់គ្រងរបស់គយ ក្នុងភណ្ឌាគារគយមានដែនកំណត់ដែលរាប់បញ្ចូល៖

- ចលនាទំនិញចូលក្នុងភណ្ឌាគារ
- ចលនាទំនិញសន្និធិក្នុងភណ្ឌាគារ
- ការផ្ទេរទំនិញទៅ ឬមកពីភណ្ឌាគារគយមានដែនកំណត់ផ្សេងទៀត
- ការធ្វើសហគ្រាសកម្មផ្សេងៗ ដូចជា ការដេរប៉ះស្រោមសម្បកវិហក ការរៀបចំកញ្ចប់ទំនិញឡើងវិញ ការជ្រើសរើស ឬវេចខ្ចប់ឡើងវិញជាដើម
- ការយកទំនិញចេញពីភណ្ឌាគារ។

រដ្ឋបាលគយត្រូវធ្វើការផ្ទៀងផ្ទាត់ជាប្រចាំរវាងសំណុំឯកសារ និងទំនិញជាក់ស្តែងក្នុងភណ្ឌាគារដើម្បីឃ្លាំមើលអនុលោមភាព។

ការខកខានរក្សាទុកឱ្យបានត្រឹមត្រូវនូវសំណុំឯកសារទាំងនេះ ប្រតិបត្តិករកណ្តាគារគយមានដែនកំណត់ ត្រូវទទួលរងនូវការពិន័យតាមច្បាប់ជាធរមាន។ ក្នុងករណីដែលការមិនគោរពអនុលោមភាពនៅតែបន្ត ប្រតិបត្តិករអាចរងនូវការព្យួរ ឬលុបចោលនូវអាជ្ញាបណ្ណកណ្តាគារគយមានដែនកំណត់នេះ។

ប្រការ ១០ .-

ទំនិញអាចរក្សាទុកក្នុងកណ្តាគារគយមានដែនកំណត់ រហូតដល់រយៈពេលមួយរយប៉ែតសិប (១៨០)ថ្ងៃ គិតពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ។ ប្រសិនបើទំនិញស្ថិតក្នុងសភាពល្អ រយៈពេលកំណត់នេះអាចត្រូវបានពន្យាររហូតដល់រយៈពេលមួយរយប៉ែតសិប (១៨០)ថ្ងៃ បន្តទៀត ដោយរដ្ឋបាលគយ តាមការស្នើសុំរបស់ប្រតិបត្តិករកណ្តាគារគយមានដែនកំណត់ មុនពេលផុតរយៈពេលកំណត់។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានសិទ្ធិសម្រេចកំណត់ប្រភេទមុខទំនិញនិងរយៈពេលមិនលើសមួយរយប៉ែតសិប (១៨០)ថ្ងៃ អាស្រ័យទៅតាមលក្ខណៈបច្ចេកទេស គុណភាព សុពលភាព និងភាពចាំបាច់ផ្សេងទៀតនៃមុខទំនិញដែលអាចធ្វើសន្និធិក្នុងកណ្តាគារគយមានដែនកំណត់។

ប្រការ ១១ .-

ទំនិញដែលស្ថិតក្នុងកណ្តាគារគយមានដែនកំណត់អាចត្រូវបានលក់ ឬផ្ទេរ។ អ្នកនាំចូលឬម្ចាស់ទំនិញត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់រដ្ឋបាលគយ ពីការផ្ទេរកម្មសិទ្ធិនេះ។

ទំនិញដែលស្ថិតក្នុងកណ្តាគារគយមានដែនកំណត់អាចត្រូវបានផ្ទេរទៅ កណ្តាគារគយមានដែនកំណត់មួយទៀត ក្រោមការត្រួតពិនិត្យគយ។ សំណុំឯកសារពាក់ព័ន្ធនឹងការផ្ទេរទំនិញដូចនេះត្រូវដាក់ជូនរដ្ឋបាលគយ។

ប្រការ ១២ .-

ទំនិញដែលយកចេញពីកណ្តាគារគយមានដែនកំណត់សម្រាប់នាំចេញ ត្រូវជាកម្មវត្ថុនៃការតម្កល់ប្រតិវេទន៍គយនាំចេញ ហើយពុំត្រូវជាប់ពន្ធ អាករនាំចូល ឬនាំចេញទេ លើកលែងតែទំនិញក្នុងស្រុកដែលអាចជាប់អាករនាំចេញ។

ទំនិញដែលយកចេញពីកណ្តាគារគយមានដែនកំណត់ សម្រាប់ដាក់ឱ្យប្រើប្រាស់ក្នុងស្រុកត្រូវជាប់ពន្ធនិងអាករតាមអត្រាពន្ធនិងអាករជាធរមាននៃថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ ដើម្បីយកទំនិញចេញពីកណ្តាគារ។

ប្រការ ១៣ .-

ម្ចាស់ទំនិញក្នុងកណ្តាគារគយមានដែនកំណត់ អាចត្រូវបានអនុញ្ញាតដោយរដ្ឋបាលគយ ដើម្បីពិនិត្យមើលទំនិញ ដកគំរូទំនិញ និងធ្វើប្រតិបត្តិការចាំបាច់នានា ក្នុងគោលបំណងថែរក្សាទំនិញទាំងនោះដោយមិនផ្លាស់ប្តូរលក្ខណៈសំខាន់នៃទំនិញនេះ រួមមាន ការបាញ់ថ្នាំសម្លាប់សត្វល្អិត ការសម្ងួត ការសម្អាត ការសាកល្បង ការដេរប៉ះស្រោមសម្បករហែក ការបិទស្លាកសម្គាល់ ការសរសេរចំណាំ ការរៀបចំកញ្ចប់ទំនិញឡើងវិញ ការជ្រើសរើសឬវេចខ្ចប់ឡើងវិញជាដើម។

ប្រការ ១៤ .-

ស្ថិតក្នុងកាលៈទេសៈជាក់ស្តែង ការកែច្នៃ បំប្លែង និងផលិតទំនិញក្នុងភណ្ឌាគារគយមានដែនកំណត់ (Customs Bonded Warehouse) អាចត្រូវបានអនុញ្ញាតដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរូបភាពជាភណ្ឌាគារផលិតកម្មមានដែនកំណត់ស្ថិតក្រោមការគ្រប់គ្រងរបស់គយ (Customs Manufacturing Bonded Warehouse) ដោយអនុលោមតាមបញ្ញត្តិនានានៃប្រកាសនេះដែលពាក់ព័ន្ធនឹងការចេញអាជ្ញាបណ្ណ។ ប្រតិបត្តិករនៃភណ្ឌាគារដូចនេះ ត្រូវបានអនុញ្ញាតឱ្យនាំចូលដោយព្យួរពន្ធនិងអាករនាំចូលនូវមុខទំនិញជាវត្ថុធាតុដើម ធាតុផ្សំ គ្រឿងម៉ាស៊ីន ឧបករណ៍ និងសម្ភារៈបរិក្ខារដែលត្រូវប្រើដោយផ្ទាល់ក្នុងការផលិត ឬកែច្នៃទំនិញ។

អាជ្ញាបណ្ណប្រតិបត្តិការភណ្ឌាគារផលិតកម្មមានដែនកំណត់ ត្រូវបញ្ជាក់នូវបញ្ជីមុខទំនិញជាវត្ថុធាតុដើម ធាតុផ្សំ គ្រឿងម៉ាស៊ីន ឧបករណ៍ និងសម្ភារៈបរិក្ខារដែលអាចនឹងត្រូវនាំចូលដោយព្យួរពន្ធនិងអាករ។

ទំនិញនាំចូលដែលត្រូវបានយកពីភណ្ឌាគារផលិតកម្មមានដែនកំណត់ សម្រាប់ការប្រើប្រាស់ក្នុងប្រទេសត្រូវជាប់ពន្ធនិងអាកដោយអនុលោមតាមបញ្ញត្តិមាត្រា ៤៩ នៃច្បាប់ស្តីពីគយ។

ផលិតផលសម្រេចដែលយកចេញពីភណ្ឌាគារផលិតកម្មមានដែនកំណត់ សម្រាប់ការប្រើប្រាស់ក្នុងប្រទេសត្រូវជាប់ពន្ធនិងអាករ លើតម្លៃវត្ថុធាតុដើម ឬធាតុផ្សំដែលបាននាំចូលដោយព្យួរពន្ធនិងអាករ ហើយបានប្រើប្រាស់ក្នុងការផលិត។

ពន្ធនិងអាកទាំងនេះ ត្រូវប្រមូលផ្តែកតាមតារាងពន្ធគយ ហើយអត្រាពន្ធនិងអាកដែលត្រូវប្រមូល គឺជាអត្រានៅក្នុងថ្ងៃចុះបញ្ជីការប្រតិវេទន៍គយនៅពេលដែលទំនិញទទួលបានការអនុញ្ញាតឱ្យយកចូលភណ្ឌាគារនេះ។

ប្រការ ១៥ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចេញអាជ្ញាបណ្ណសម្រាប់ប្រតិបត្តិការកែច្នៃ ឬចម្រាញ់តេលសិលាធៅ ឬបីទីមខនិជ ដើម្បីទទួលបានផលិតផលតេលសិលា ត្រូវដាក់ឱ្យស្ថិតក្រោមរបបភណ្ឌាគារផលិតកម្មមានដែនកំណត់ក្រោមការគ្រប់គ្រងរបស់គយ ដោយអនុលោមតាមបញ្ញត្តិនានានៃប្រកាសនេះដែលពាក់ព័ន្ធនឹងការចេញអាជ្ញាបណ្ណ។

អាជ្ញាបណ្ណដូចនេះត្រូវកំណត់នូវអាណត្តិ និងលក្ខខណ្ឌសម្រាប់ការធ្វើប្រតិបត្តិការភណ្ឌាគារផលិតកម្មមានដែនកំណត់ក្រោមការគ្រប់គ្រងរបស់គយ។

ការព្យួរពន្ធនិងអាកអាចត្រូវបានផ្តល់ឱ្យសម្រាប់ការនាំចូលតេលសិលាធៅ ឬបីទីមខនិជសម្រាប់កែច្នៃដើម្បីនាំចេញ ដោយអនុលោមតាមបញ្ញត្តិកថាខណ្ឌទី ២ មាត្រា ៤៩ នៃច្បាប់ស្តីពីគយ។

ប្រការ ១៦.-

ប្រកាសលេខ ១១៦ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីកណ្តាគារគយមានដែនកំណត់ ត្រូវទុកជានិរាករណ៍។

ប្រការ ១៧.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីទទួលបន្ទុកជាអគ្គនាយក ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការ និងប្រធានអង្គភាពនានាដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រតិបត្តិករពាក់ព័ន្ធ ត្រូវទទួលបន្ទុកដើម្បីអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៦ កើត ខែ ភាទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ ១៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ